# ៣- រឿង កូន ៤ នាក់មិនបម្រើឪពុក

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ជាអ្នករកស៊ីលក់ដូរ មានធនធានគ្រាន់បើ គាត់មានកូនប្រុស៤នាក់មានអាយុគ្រប់ការទាំងអស់ ។

ក្រោយពីពេលដែលប្រពន្ធអនិច្ចកម្មទៅ គាត់ទ្រាំនៅជាពោះម៉ាយពុំយកប្រពន្ធទៀតទេ នៅជាមួយនឹងកូនប្រុសៗអស់១ឆ្នាំ មានការលំបាកដោយខ្វះស្រីមេផ្ទះជាអ្នកចម្អិនអាហារ និងជួយមើលថែទាំរបស់ទ្រព្យកំប៉ិកកំប៉ុកក្នុងផ្ទះ គាត់ក៏រៀបការប្រពន្ធឱ្យកូនច្បង ហើយយកកូនប្រសាស្រីមកនៅជាមួយចែកទ្រព្យអស់មួយចំណែក ឱ្យដាច់ស្រឡះទៅកូនច្បងរួចទៅ ។

លុះរំលងមួយឆ្នាំក្រោយមកទៀត គាត់រកប្រពន្ធឱ្យកូនទី២ចែកទ្រព្យ ១ ចំណែកឱ្យដូចគ្នា ។

តមក គាត់រៀបការកូនទី ៣ ចែកទ្រព្យ ១ចំណែកឱ្យទៀត ។ ដល់ឆ្នាំជាគម្រប់ ៤ ក៏រៀបការឱ្យកូនទី ៤ចែកទ្រព្យ ១ចំណែកទៀតដែរ ។ នៅសល់តែផ្ទះ ១ខ្នងពុំបានចែក គាត់ទុកនៅទាំងអស់គ្នា ។

ដែលគាត់ចែកទ្រព្យរបស់ឱ្យអស់រលីងពីខ្លួន ដូច្នេះមកពីគិតថា ឱ្យស្រឡះខ្លួនគាត់ ហើយនៅទំនេរស្ងៀម ចាំឱ្យកូនរកស៊ីចិញ្ចឹមវិញ រហូតដល់ស្លាប់ " ប៉ុន្តែគំនិតគាត់គិតនេះខុសស្រឡះ ។

កាលដែលគាត់នៅជាមួយកូនប្រុស ៤នាក់ កូនទាំងនោះស្រឡាញ់បងប្អូនណាស់ពុំដែលបែកចិត្តគំនិតពីឪពុក និងបងប្អូនឡើយ ។

លុះបានប្រពន្ធមករៀងខ្លួនហើយ ក៏បែកចិត្តគំនិតផ្សេងៗ ពីគ្នានៅរួមជាមួយគ្នាពុំសូវបានសុខ ចេះតែស្មៀបរមាស់ បន្តិចទាស់នេះ បន្តិចទាស់នោះក៏នាំគ្នាចុះចេញពីផ្ទះកំណើត ទៅរកសង់ផ្ទះនៅទីទៃពីគ្នាទាំងអស់ ចោលតាឪពុកពោះម៉ាយឱ្យនៅតែឯកោអនាថា ។

កាលកូនទាំង ៤នាក់ ទើបនឹងចុះចេញពីផ្ទះឪពុកទៅថ្មីៗ នៅហុចបាយហុចចំណីតាឪពុកបន្តិចបន្តួចរាល់ៗថ្ងៃ លុះមានកូនខ្ចីគ្រប់គ្នា ជួនពេលប្តីរវល់ដើរទៅជួញស្រុកឆ្ងាយភរិយានៅផ្ទះអាងតែប្តីមិននៅ និងអាងមានកូនខ្ចីផង ក៏បង្អង់ ជួនបាយទឹកឪពុកក្មេក ដោយមេខ្លះគិតថាប្រហែលប្អូនគេឱ្យហើយ មេខ្លះគិតថាបងឯណោះគេឱ្យហើយ កូនប្រសានាំគ្នាគិតដូច្នេះតែរៀងខ្លួនយូរៗថ្ងៃទៅតានោះអត់បាយ ១ពេលក៏មាន ២ពេលក៏មាន ។

វេលាប្តីមកពីរកស៊ីវិញដឹងរឿងនេះ បានស្តីបន្ទោសប្រពន្ធ នាងភរិយាខ្លះដោះសាថា កូនឈឺ ខ្លះថា ខ្លួនពុំនៅរវល់ទៅជួយញាតិជិតខាងស្រេចតែមេប្រពន្ធវាដឹកមុខយ៉ាងណា ប្តីតាមវាទាំងអស់ ។

ចំណែកតាពោះម៉ាយ អត់បាយគ្មានសំពត់អាវស្លៀកពាក់ដល់ថ្នាក់ដើរសុំទានគេបរិភោគ រងទុក្ខវេទនាពន់ពេកនឹងលក់ផ្ទះៗចាស់គ្រាំគ្រាពុំបានថ្លៃប៉ុន្មានផង ហើយគ្មានជ្រកនៅផង ។

កាលនោះ មានបុរសម្នាក់ នៅកម្លោះ មានចិត្តសប្បុរសហើយជាអ្នករៀនសូត្រចេះដឹងច្បាប់ទម្លាប់ស្គាល់គុណទោសច្រើន ផ្ទះនៅភូមិជិតគ្នាដើរមកឃើញតានោះវេទនាដូច្នោះ មានចិត្តអាណិតក្រៃពេកក៏សាកសួរថា " លោកតា ! ខ្ញុំធ្លាប់ឃើញលោកតាពីដើម ជាអ្នកមានគ្រាន់បើឪពុកម្តាយខ្ញុំក៏ធ្លាប់ទីពឹងលោកតាខ្លះដែរ ម៉េចក៏ឥឡូវនេះលោកតាវេទនាខ្លាំងម្ល៉េះ ក្រែងលោកតាមានកូនប្រុសៗដល់ទៅ ៤នាក់ដែរឬ ម្តេចក៏កូននោះ វាមើលបំណាំមិនថែទាំលោកតាសោះ ? ក្រែងទ្រព្យរបស់លោកតាមានសល់ទុកខ្លះដែរឬ ម្តេចបានជាលោកតាមិនយកទៅទិញគ្រឿងបរិភោគប្រើប្រាស់ " ។

តាចាស់ប្រាប់ទៅវិញថា " ឱហ្ន៎ ! លោកចៅអើយ ! លាក់បាំងអីពីដើមតាមានទ្រព្យគ្រាន់បើពិតមែន ប៉ុន្តែតាអាណិតស្រឡាញ់កូនពេកក៏ចែកឱ្យវាគ្រប់គ្នាអស់រលីងពីខ្លួនទៅ គិតថាឱ្យវាចិញ្ចឹមតាវិញ ឥឡូវពួកវាមានប្រពន្ធហើយថែមទាំងមានកូនទៀត វាឃើញឯងអស់ទ្រព្យរលីងពីខ្លួន វាឥតនឹកនារកតាសោះ វាតាមតែប្រពន្ធទាញទៅ

ចូលរន្ធក្តាមក៏វាចូលដែរ ខ្លួនតាសព្វថ្ងៃឈឺផងនៅតែម្នាក់ឯងម៉ង់ៗ វេទនាជាទីបំផុត ដេកសម្រក់តែទឹកភ្នែកជោកខ្នើយអស់ហើយ បាយព្រឹកជាបាយល្ងាចចួនកាលអត់មួយពេលក៏មាន នឹងធ្វើការរកស៊ីអ្វីក៏មិនកើតពីព្រោះចាស់ជរាគ្រាន់តែដើរស្ទើរតែមិនរួចទៅហើយ ដូចលោកចៅឃើញស្រាប់តាដេកចាំតែដល់ថ្ងៃស្លាប់ទេ " ។

ចៅកម្លោះឈាន់មាត់ថា : " យីអើ ! កូនតាមានចិត្តអាក្រក់ដល់ម្លឹងហ្ន៎បើអីចឹងលោកតាកុំភ័យ ខ្ញុំមានឧបាយមួយ ធ្វើឱ្យលោកតាបានសុខកាយសប្បាយចិត្តដូចពីដើមវិញ លោកតាធ្វើតាមខ្ញុំ ឱ្យលោកតារកពាងមានមាត់តូចល្មមមួយ ជុះអាចម៍និងនោមឱ្យពេញហើយរកកំណាត់សំពត់រុំបិទមាត់ឱ្យជិត ជីកកប់ក្នុងដីជិតជើងសសរទ្រូងផ្ទះហើយបើមានអ្នកណាដើរមកឱ្យលោកតានិយាយប្រាប់គេថា ខ្ញុំនៅសល់ កំណប់ប្រាក់មាស ១ ពាងកប់ទុក ពុំទាន់ចែកឱ្យកូនណានៅឡើយ ចាំមើលកូនណាចិត្តបានដឹងគុណបើខ្ញុំទៀបស្លាប់នឹងប្រគល់ឱ្យទៅកូននោះ លោកតានិយាយប្រាប់មនុស្សដែលជួបកុំខានក្នុងរវាងប៉ុន្មានថ្ងៃខែខាងមុខនេះកុំឱ្យលោកតាដើរសុំទានគេទៀត ចាំខ្ញុំយកបាយទឹកមកជូនពិសាកុំព្រួយ " ។

តាចាស់ ក៏តាំងធ្វើតាមចៅចិត្តសប្បុរសទាំងអស់ ។ លុះបានប្រហែល ៥ថ្ងៃសំដីតានោះ បានដឹងដល់កូនប្រុសនិងកូនប្រសាទាំង ៨ នាក់ វាមានចិត្តលោភចង់បានកំណប់តែរៀងខ្លួន ក៏នាំគ្នាយកបាយទឹកម្ហូបចំណីផ្លែឈើទុំខ្ចីគ្រប់មុខ និងខោអាវក្រមាមកផ្គាប់ផ្គុនជូនតាឪពុករៀងរាល់ថ្ងៃ ពុំមានខ្វះថ្ងៃណាមួយឡើយ តាចាស់បានសះជារោគមានសាច់ឈាមស្រស់បស់ មានកម្លាំងពលំ សុខកាយសប្បាយចិត្ត តាំងពីថ្ងៃនោះមករហូតដល់អស់អាយុ ។ លុះតាស្លាប់ហើយ កូនក៏នាំគ្នាធ្វើបុណ្យអធិកអធមតាមទំនៀមរួចស្រេច ។

កូនទាំង ៤នាក់ និងកូនប្រសាគិតនាំគ្នាគាស់ពាងកំណប់ចែកគ្នា ប៉ុន្តែ ក្រែងចែកមិនស្មើភាគនាំឈ្លោះប្រកែកគ្នា ក៏ទៅរកគ្រូហ្មម្នាក់ឱ្យមកជួយចែក លោកគ្រូនោះទទួលព្រម ប៉ុន្តែគាត់ឮថាកំណប់មាសប្រាក់ច្រើនដល់ទៅ១ពាង គាត់ចង់បាន ១ចំណែកដែរ ហើយគាត់គិតក្នុងចិត្តថា "គាត់ធ្វើមេចំណែកត្រូវបានច្រើនជាងកូនចំណែកផង "គាត់ក៏ដើររូតរះមកដល់ផ្ទះកំណប់ភ្លាម តាំងយកភួយធំមួយមករុំ ជួតក្បាលធំទើងមើងធ្វើឱ្យខ្ពង់កណ្តាលដូចគេខ្ទូលជើងឆ្នាំងផ្ការ ក៏តាំងអង្គុយពែនភ្នែនលើផ្ទៃដីរាបរលីង ធ្មេចភ្នែកសង្រួមស្មិងស្មាធិ៍ ឈមមុខត្រង់ទៅទិសខាងកើត ហើយគាត់ប្រាប់កូនទាំង៤នាក់ឱ្យទៅគាស់យកពាងកំណប់មក ប៉ុន្តែគាត់ហាមថាកុំអាលស្រាយមាត់ពាងក្រែងខុសត្រណមចាំគាត់បង្គាប់សិន លុះយកពាងមកដល់ហើយគាត់ឱ្យកូនទាំង ៤នាក់ឈរគ្រប់ទិសទាំង៤ ធ្មេចភ្នែកយកដៃទាំងអស់គ្នាចាប់លើកពាងទ្រស្គួយបិទទូលលើក្បាល ហើយសឹមស្រាយចំណង មាត់ពាងនាំគ្នាផ្អៀងមាត់ពាងស្រោចកំណប់មកលើក្បាលគាត់បើកំណប់ជ្រុះធ្លាក់ទៅទិសណាប៉ុន្មានៗ ត្រូវបានទៅអ្នកឈរកំណាន់ទិសនោះៗកំណប់ណានៅសល់ទើរលើផ្នួតក្បាលគាត់ត្រូវបានជារង្វាន់លោកគ្រូទាំងអស់ ។

កូនទាំង ៤នាក់ក៏ចាប់ធ្វើតាមបង្គាប់លោកគ្រូមិនហ៊ានឱ្យល្អៀង ។ ភរិយាទាំង ៤នាក់ឈរកាន់កញ្ជើរៀងខ្លួនចាំកើប ។

ក្នុងពេលដែលចែកកំណប់នោះ មានអ្នកស្រុកជិតខាងទៅចាំមើលដែរ ។

និមិត្ត តែគេលើកពាងបិទទូលរួច ស្រាយមាត់ពាងផ្អៀងចាក់ឈ្ងូរមក " ទឹកម៉ាំត្រាំលាមកច្រើនខួប " ហូរឆស្រោចលើក្បាលលោកគ្រូពេញកំពុង ហើយខ្ទាត់បាចសាចចេញទៅគ្រប់ទិសប្រឡាក់ប្រឡូសពាសពេញមុខមាត់និងសំពត់អាវរហូតដល់នាងប្រពន្ធទាំង ៤នាក់ទៀតលោកគ្រូបានចំណែកច្រើនជាងគេ ធុំក្លិនខ្មោះថាមិនត្រូវ គេឃើញលោកគ្រូស្រមូវៗ បាត់មុខមាត់រូបរាងអស់ ខំក្រោកឡើងសោះកក្រោះខ្មាសអស់ពួកបរិស័ទដែលឈរចាំមើល ពួកបរិស័ទក៏ផ្អើលខំរត់ប្រញាប់ចេញប្រដេញគ្នាទៅផ្ទះរៀងៗខ្លួន ទើបលោកគ្រូស្រែកជេរកែសំនួនទៅកូនទាំង ៤ នាក់ និង កូនប្រសាថា " ខ្មោចមេដែង អាដែងទាំងអស់គ្នា អាមេអស់នេះ បានធ្វើបាបខ្មោចឪពុកវាច្រើនណាស់ហើយមើលទៅ បានជាកំណប់មាសប្រាក់អន្តរាយក្លាយទៅជាអាចម៍នោមប្រឡាក់ខ្លួនអញអស់ដូច្នេះយី ! ខ្មោចអាផេះ មេកំផេះអស់នេះខូចមែន " ។

លោកគ្រូនិងកូនសិស្សនាំគ្នារត់របើស លោតទម្លាក់ខ្លួនទៅក្នុងទន្លេប្រូងខំត្រាំទឹកលាងបាបអស់ ១ម៉ោងម្នាក់ៗ រួចនាំគ្នាឡើងទៅលើផ្ទះរៀងៗ ខ្លួនបានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ខ្មាសគេតកូនតចៅ ។